# ការសម្ភាសរបស់អ៊ុំប្រុស ទី មាស

**កៈ អ្នកសម្ភាសឈ្មោះ ជាង ស៊ីអ៊ាវ　　ខៈ អ្នកទទួលការសម្ភាសឈ្មោះ ទី មាស**

## ការសង្ខេបប្រវត្តិរបស់អ៊ុំប្រុស ទី មាស

អ៊ុំប្រុសឈ្មោះ ទីមាស មានអាយុ៥៣ ឆ្នាំនៅក្នុងឆ្នាំ២០១៩ មានភេទប្រុស មានទីលំនៅបច្ចុប្បន្ននៅភូមិគោកស្រុក ឃុំតាំងក្រសៅ ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ។

កៈ ចឹងជាដំបូងខ្ញុំអរគុណច្រើនអ៊ុំដែរបានអោយខ្ញុំពិភាក្សាជាមួយអ៊ុំដែរទាក់ទងពីប្រវត្តិរបស់អ៊ុំ ហើយការសម្ភាសទាំងអស់នេះត្រូវបានរៀបចំដោយសកលវិទ្យាល័យមួយដែរមានឈ្មោះថាBYU ហើយដោយសារតែសកលវិទ្យាល័យមានគោលបំណងចង់រក្សាពីប្រវត្តិប្រជាជនខ្មែរ ដើម្បីទុកអោយកូនចៅជំនាន់ក្រោយពួកគាត់បានស្គាល់ហ្នឹងបានដឹង ពីប្រវត្តិឪពុកម្ដាយហ្នឹងដូនតា ចឹងសំរាប់អ៊ុំយល់ព្រមដើម្បីអោយខ្ញុំដាក់ការសម្ភាសទាំងអស់ហ្នឹងទៅក្នុងវេបសាយសាលាទេអ៊ុំ?

ខៈ បាទ!

កៈ បាទចឹងសំរាប់ខ្ញុំជាអ្នកសម្ភាសអ៊ុំខ្ញុំមានឈ្មោះថាជាង ស៊ីអ៊ាវហើយថ្ងៃខែដែរខ្ញុំសម្ភាសអ៊ុំគឺនៅថ្ងៃទី៧ ខែ៣ឆ្នាំ២០១៩ហើយការម្ភាសទាំងអស់ហ្នឹងគឺធ្វើឡើងនៅភូមិអើគោកស្រុក?

ខៈ គោកស្រុក។

កៈ ឃុំតាំងក្រសៅ?

ខៈ តាំងក្រសៅ ស្រុកប្រាសាទសំបូរ។

កៈ ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ?

ខៈ ខេត្តកំពង់ធំ។

កៈ ចឹងសំរាប់អ៊ុំអើអ៊ុំឈ្មោះពេញរបស់អ៊ុំម៉ងទាំងត្រកូលម៉ងឈ្មោះអីគេអ៊ុំ?

ខ៖ ឈ្មោះទី មាស។

ក៖ តេង មាស?

ខ៖ ទី។

ក៖ ទី មាស?

ខ៖ បាទ!

ក៖ អ៊ំចុះមានឈ្មោះហៅក្រៅអត់អ៊ុំ?

ខ៖ អត់ទេអត់មាន។

ក៖ ចុះកាលពីក្មេងធ្លាប់មាននរណាហៅឈ្មោះអ៊ុំអីផ្សេងទេអ៊ុំ?

ខ៖ អត់ទេកាលពីក្មេងមកមានឈ្មោះមួយ។

ក៖ អ៊ំបាទអ៊ុំចុះអ៊ុំគិតថាសព្វថ្ងៃអ៊ុំអើអាយុប៉ុន្មានដែរអ៊ុំ?

ខ៖ ហាបីហើយ!

ក៖ អ៊ំចុះអ៊ុំកើតនៅថ្ងៃខែឆ្នាំណាអ៊ុំចាំទេ?

ខ៖ អត់ចាំទេ។

ក៖ អត់ចាំទេណោះអ៊ុំ?

ខ៖ បាទ!

ក៖ ចុះលក្ខណះឆ្នាំជូត ឆ្លូវ ខាល ថោះអ៊ុំឆ្នាំអីគេអ៊ុំ?

ខ៖ ឆ្នាំមមែ។

ក៖ មមែណោះអ៊ុំ?

ខ៖ បាទ!

ក៖ ចុះអ៊ុំកើតស្រុកកំណើតរបស់អ៊ុំម៉ងអ៊ុំកើតនៅណាអ៊ុំ?

ខ៖ នៅចាស់ជ្រុំ។

ក៖ ចាស់ជ្រុំ?

ខ៖ ចាស់ជ្រុំនៅទូល។

ក៖ អ៊ុំភូមិអីឃុំអីអ៊ុំ?

ខ៖ ឃុំ..!

ក៖ តាំងក្រសៅហ្នឹងដែរ?

ខ៖ អត់ទេអើឃុំជ័យ។

ក៖ ឃុំជ័យ?

ខ៖ ឃុំជ័យ។

ក៖ ចុះភូមិ?

ខ៖ អត់ទេភូមិចាស់ជ្រុំ។

ក៖ ចាស់..?

ខ៖ ឃុំជ័យ។

ក៖ ឃុំជ័យស្រុក?

ខ៖ ស្រុកប្រាសាទសំបូរ។

ក៖ អ៊ុំចឹងអើប្រសាទសំបូរដែរណោះអ៊ុំ?

ខ៖ បាទ!

ក៖ អោយបាទអោយខេត្តកំពង់ធំ?

ខ៖ ខេត្តកំពង់ធំ។

ក៖ ចឹងសំរាប់អ៊ុំគិតថាអ៊ុំមានបងប្អូនបង្កើតចំនួនប៉ុន្មាននាក់អ៊ុំ?

ខ៖ បងប្អូនបង្កើតប្រាំមួយនាក់ប៉ុនស្លាប់អស់ហើយនៅសល់តែពីរនាក់។

ក៖ អ៎ូបងៗរបស់អ៊ុំហោស?

ខ៖ បាទបង!

ក៖ ចុះនៅពីរហ្នឹងនៅប្អូនអ៊ុំរឺក៏បងអ៊ុំ?

ខ៖ បង!

ក៖ បងអ៊ុំទៀតហោស?

ខ៖ បាទ!

ក៖ មានស្រីប៉ុន្មានប្រុសប៉ុន្មានអ៊ុំ?

ខ៖ មានស្រីមួយហោស!

ក៖ ប្រុសបួន?

ខ៖ ប្រុសប្រាំ។

ក៖ ប្រុសប្រាំណោះអ៊ុំណោះចឹងអ្នកដែរស្លាប់ហ្នឹងគឺស្រីមួយប្រុសបួន ប្រុសបី?

ខ៖ ប្រុសបី!

ក៖ អ៎ូប៉ុន្តែអ៊ុំអាចប្រុសឈ្មោះពួកគាត់បានអត់ថាពួកគាត់មានឈ្មោះអីខ្លះអត់អ៊ុំ?

ខ៖ បាទ!

ក៖ ឈ្មោះអី?

ខ៖ ទីណ្ហូតបងគេបង្អស់។

ក៖ អ៎ូចុះបន្ទាប់មកទៀត?

ខ៖ ទីអុន។

ក៖ អ៎ូបន្ទាប់មកទៀតអ៊ុំ?

ខ៖ ទីផុន។

ក៖ ទីផុនបន្ទាប់មកទៀតបានអ៊ុំទីប៉ុន្មានអ៊ុំ?

ខ៖ ខ្ញុំទីជិតបញ្ចប់។

ក៖ ទីជិតបញ្ចប់ណោះអ៊ុំណោះចុះទីបួនអ៊ុំ?

ខ៖ ទីជីន។

ក៖ ទីជីន?

ខ៖ បាទ!

ក៖ ចុះទីប្រាំអ៊ុំ?

ខ៖ បាទ!

ក៖ ទីប្រាំមួយ?

ខ៖ ជីនហ្នឹងឯងទីប្រាំមួយហោស!

ក៖ ទីប្រាំមួយជីន?

ខ៖ បាទ!

ក៖ ចុះទីបួនអ៊ុំ?

ខ៖ ទីរួនអ៊ុំ។

ក៖ អ៊ុំ?

ខ៖ បងជីន។

ក៖ អូ៎បាទចុះគាត់អ្នកនៅរស់ហ្នឹងគាត់ទីប៉ុន្មានអ៊ុំ?

ខ៖ គាត់..!

ក៖ អ្នកដែរនៅរស់ជាមួយអ៊ុំហ្នឹងទីបួនមែន?

ខ៖ នៅរស់បងខ្ញុំហោសទីបី។

ក៖ ទីបីហោសអ៊ុំហោស?

ខ៖ ទីបី។

ក៖ អូ៎!

ខ៖ ទីបីរំលងមួយមកបានស្លាប់មួយមកបានខ្ញុំ។

ក៖ អូ៎ចុះអើអ៊ុំកើតអីបានពួកគាត់ស្លាប់អ៊ុំជំនាន់ប៉ុលពតហោសគេសំលាប់ហោស?

ខ៖ អត់ទេបាត់ខ្លួនបណ្ដោយ។

ក៖ អើម៉េចចឹងអ៊ុំ?

ខ៖ ជំនាន់ណោះមាននរណាស្រាវជ្រាវងាប់គប់ចោលៗ។

ក៖ អូ៎ដល់ពេលចឹងយើងអត់ដឹងថាពួកគាត់ទៅណាទេណោះ?

ខ៖ បាទ!

ក៖ បាទអ៊ុំបាទចុះអ៊ុំគិតថាចឹងអ៊ុំធ្លាប់មានអនុស្សាវរីយ៍អីជាមួយពួកបងប្អូនអ៊ុំកាលនៅក្មេង
អត់អ៊ុំធ្លាប់ធ្វើអីគេខ្លះជាមួយពួកគាត់អត់?

ខ៖ បាទ?

ក៖ អ៊ុំធ្លាប់មានអនុស្សាវរីយ៍អីជាមួយបងប្អូនអ៊ុំកាលនៅក្មេងអត់អ៊ុំ?

ខ៖ ខ្ញុំកាលនៅក្មេងអត់ទាន់ដឹងអីទេជំនាន់ណុងប៉ុលពតរៀងកាលណុងទៅនៅកងចល័ត។

ក៖ បាទអ៊ុំបាទចុះអ៊ុំគិតថាដូចជាបងរបស់អ៊ុំដែរគាត់នៅរស់ហ្នឹងគាត់នៅណាឥឡូវអ៊ុំ?

ខ៖ នៅថ្មល់បែក។

ក៖ កំពង់ចាម?

ខ៖ ថ្មល់បែកនេះ។

ក៖ កំពង់ធំគាត់ធ្វើអីគេនៅណុងអ៊ុំ?

ខ៖ គ្មានធ្វើអីទេឥឡូវគាត់រត់ឡានតាក់ស៊ីតិចៗ។

ក៖ អូ៎បាទអ៊ុំបាទចុះអ៊ុំគិតថាចឹងដូចជាឪពុករបស់អ៊ុំគាត់ឈ្មោះអីគេអ៊ុំ?

ខ៖ ទី។

ក៖ ឈ្មោះទីប៉ុន្តែត្រកូលគាត់ឈ្មោះអីគេអ៊ុំ?

ខ៖ អៀង។

ក៖ អៀង ទី?

ខ៖ អៀង ទី។

ក៖ អូ៎បាទអ៊ុំបាទចុះអ៊ុំគិតថាអើម្តាយរបស់អ៊ុំវិញគាត់ឈ្មោះអីគេអ៊ុំ?

ខ៖ ឈ្មោះនួន។

ក៖ ឈ្មោះអីគេនួនទៅ?

ខ៖ អៀង។

ក៖ អៀង នួន?

ខ៖ បាទអ៊ុច នួន

ក៖ អូ៎ អ៊ុច នួន?

ខ៖ អ៊ុច នួន។

ក៖ អូ៎បាទអ៊ុំបាទចុះអ៊ុំគិតថាឪពុកម្តាយរបស់អ៊ុំគាត់អ្នកស្រុកនៅហ្នឹងរឺនៅណាអ៊ុំ?

ខ៖ ខ្ញុំនៅចាស់ជ្រុំតើ!

ក៖ អូ៎ចឹង!

ខ៖ បានប្រពន្ធនៅនេះ។

ក៖ អូ៎ចឹងមានន័យថាស្រុកឪពុកម្តាយរបស់អ៊ុំនៅចាស់ជ្រុំណោះបានប្រពន្ធនៅនេះ?

ខ៖ បាទ!

ក៖ ដល់ពេលបានប្រពន្ធមកមកនៅខាងប្រពន្ធនៅហ្នឹង?

ខ៖ នៅខាងប្រពន្ធ។

ក៖ អូ៎បាទអ៊ុំចុះអ៊ុំគិតថាដូចជាឪពុករបស់អ៊ុំឪពុកម្ដាយរបស់អ៊ុំឥឡូវគាត់ស្លាប់ហើយណេះ?

ខ៖ ស្លាប់អស់ហើយ!

ក៖ ចឹងឪពុកម្ដាយអើឪពុករបស់អ៊ុំកាលគាត់នៅរស់គាត់ធ្វើអីគេសំរាប់ចិញ្ចឹមជីវិត ចិញ្ចឹម ក្រុមគ្រួសារអ៊ុំ?

ខ៖ ធ្វើស្រែតើគាត់។

ក៖ ធ្វើស្រែដែរ?

ខ៖ បាទ!

ក៖ អូ៎ចុះម្ដាយអ៊ុំវិញ?

ខ៖ ស្លាប់ដែរប៉ុនធ្វើស្រែទាំងអស់គ្នា។

ក៖ អូ៎!

ខ៖ បាទ!

ក៖ បាទអ៊ុំបាទអើឪពុកម្ដាយរបស់អ៊ុំគាត់កាចរឺមួយក៏ស្លូតអ៊ុំ?

ខ៖ ឪពុកខ្ញុំស្លូតទេឪពុកខ្ញុំម៉ែខ្ញុំ។

ក៖ ឪពុកម្ដាយអ៊ុំស្លូតទេណេះ?

ខ៖ បាទ!

ក៖ អូ៎បាទអ៊ុំចុះអ៊ុំគិតថាដូចជាអ៊ុំធ្លាប់មានអនុស្សាវរីយ៍អីជាមួយឪពុកម្ដាយអ៊ុំកាលអ៊ុំនៅ ក្មេងហាសដូចជាអ៊ុំទៅស្រែ រឺមួយក៏ធ្វើអីជាមួយពួកគាត់ឃ្វាលគោ ឃ្វាលក្របីអីធ្លាប់មានទេ អ៊ុំ?

ខ៖ បាទមានអនុស្សាវរីយ៍ឃ្វាលគោក្របី។

ក៖ អូ៎ចុះគាត់ធ្លាប់មានអាទៅដូចជាបង់សំណាញ់ត្រីជាមួយឪពុកអីធ្លាប់មានដែរតើហីអ៊ំ?

ខ៖ បាទ!

ក៖ ទៅចាប់ត្រីហី?

ខ៖ បង់ត្រីរកអីអើទៅជាមួយគាត់។

ក៖ បាទអ៊ំបាទចុះអ៊ំគិតថាអើឪពុករបស់អ៊ំគាត់ធ្លាប់ប្រាប់ពីប្រវត្តិកាលគាត់នៅក្មេងទៅអ៊ំទេអ៊ំ?

ខ៖ ប្រាប់ដែរភ្លេចអស់ហើយ!

ក៖ អូ៎ភ្លេចហើយណេះអ៊ំណេះ?

ខ៖ បាទ!

ក៖ ប៉ុន្តែម្តាយអ៊ំធ្លាប់ប្រាប់ដែរ?

ខ៖ កាលណោះយូរដែរ។

ក៖ អូ៎ឪពុកម្តាយរបស់អ៊ំគាត់ស្លាប់នៅជំនាន់ណាអ៊ំប៉ុលពតហើយណេះ?

ខ៖ ទើបស្លាប់ពីរបីឆ្នាំនេះតើ!

ក៖ អូ៎!

ខ៖ គាត់ចាស់។

ក៖ បាទអ៊ំបាទ!

ខ៖ គាត់ចាស់គាត់។

ក៖ បាទអ៊ំចុះអ៊ំគិតថាដូចជាឪពុករបស់អ៊ំដូចជាយាយឪពុកម្តាយរបស់អ៊ំដូចជាដូនតាខាងឪពុកអ៊ំហាស?

ខ៖ បាទ!

កៈ អ៊ុំស្គាល់ឈ្មោះគាត់ទេ?

ខៈ អូ៎គាត់ភ្លេចអស់ហើយ!

កៈ អូ៎!

ខៈ គាត់ជួនកាលនៅរស់ជួនកាលស្លាប់អាសំលាប់មុនៗមកភ្លេចទៅ។

កៈ អូ៎បាទអ៊ុំចុះអើជូនតាខាងម្ដាយវិញអ៊ុំស្គាល់ឈ្មោះគាត់ទេ?

ខៈ ស្គាល់ពីរនាក់។

កៈ គាត់ឈ្មោះអីគេអ៊ុំ?

ខៈ អើឈ្មោះសន ហើយអ៊ុករបស់គាត់របស់ម្ដាយ។

កៈ បាទអ៊ុំបាទចុះអ៊ុំគិតថាសំរាប់ដូចជាអ៊ុំមករស់នៅហ្នឹងយូរនៅអ៊ុំ?

ខៈ នៅចូលសាមសិបឆ្នាំទេដឹង។

កៈ នៅហ្នឹងហោស?

ខៈ បាទ!

កៈ អូ៎ចឹងមានន័យថាពីមុនអ៊ុំនៅនោះអ៊ុំមកនៅហ្នឹងរហូតម៉ងហោស?

ខៈ បាទបានប្រពន្ធមកនៅហ្នឹងតែម្ដង។

កៈ បាទដាច់ប៉ុលពតហើយ?

ខៈ ដាច់..!

កៈ ឬក៏អត់ទាន់ដាច់ប៉ុលពតហើយមកនៅហ្នឹងដែរ?

ខៈ ដាច់ប៉ុលពតហើយមកអើដាច់ប៉ុលពតពីមុនមកយើងនៅរៀនសិន។

កៈ បាទអ៊ុំបាទ!

ខៈ ដល់រៀនទៅក៏ស្រឡាញ់ស្រីហោសហើយទៅក៏ដណ្ដឹងគេទៅ។

កៈ បាទអ៊ុំបាទចុះអ៊ុំគិតថាដូចជាអ៊ុំមានបងប្អូនកូនចៅទាំងខាងប្រពន្ធអ៊ុំរឺមួយក៏ខាងអ៊ុំណាម្នាក់ដែរពួកគាត់ទៅរស់នៅស្រុកក្រៅអត់អ៊ុំ?

ខៈ វាបាត់មនុស្សមិនដឹងនៅណាហ្នឹងហើយដឹងងាប់ដឹងរស់។

កៈ ប៉ុន្តែដូចជាកូនចៅអ៊ុំរឺមួយក៏ខាងប្រពន្ធអីមាននរណាគេទៅរស់នៅខាងថៃរឺមួយក៏ខាងវៀតណាមអីមានទេអ៊ុំ?

ខៈ គ្មានទេ។

កៈ អត់មានទេណោះអ៊ុំណោះ?

ខៈ បាទ!

កៈ កូនក្មួយអីក៏អត់មានដែរណោះអ៊ុំ?

ខៈ កូនក្មួយគ្មានទេ។

កៈ អូ៎បាទអ៊ុំចុះអ៊ុំចុះអ៊ុំគិតថាអើប្រពន្ធរបស់អ៊ុំគាត់ឈ្មោះអីគេអ៊ុំ?

ខៈ យួន ខុន។

កៈ យួន ខុន?

ខៈ យួន ខុត។

កៈ អូ៎យួន ខុតហោស?

ខៈ បាទខុត។

កៈ អូ៎ចុះអ៊ុំគិតថាដូចជាអើប្រពន្ធរបស់អ៊ុំឥឡូវគាត់ធ្វើអីគេអ៊ុំ?

ខៈ អត់ធ្វើអីទេធ្វើស្រែតើ!

កៈ អូ៎ប៉ុន្តែពីមុនគាត់ធ្វើស្រែណោះ?

ខៈ បាទធ្វើស្រែរហូត។

កៈ សំរាប់អ៊ុំអ៊ុំធ្វើស្រែដែរ?

ខ៖ បាទ!

ក៖ ប៉ុន្តែអ៊ុំជាងផ្ទះដែរមែនអ៊ុំ?

ខ៖ អត់ទេជួលគេតើប៉ុនជាងគេមកវ៉ៃក្តារអានោះពីរបីសន្លឹកលេង។

ក៖ អូ៎ចឹងផ្ទះហ្នឹងយើងជួលគេណោះអ៊ុំណោះ?

ខ៖ បាទជួលគេតើ!

ក៖ អូ៎បាទអ៊ុំបាទ!

ខ៖ ជាងគេអត់មកគេធ្វើបុណ្យ។

ក៖ ចុះអ៊ុំគិតថាអើអ៊ុំមានកូនបួនអ្នក?

ខ៖ បួន។

ក៖ ប៉ុន្តែកូនបងគាត់នៅណា?

ខ៖ នៅថៃ។

ក៖ នៅថៃគាត់មានគ្រួសារនៅអ៊ុំ?

ខ៖ មានហើយទាំងប្តីទៅទាំងប្តីទាំងប្រពន្ធ។

ក៖ ប៉ុន្តែមានកូនហើយណោះអ៊ុំ?

ខ៖ កូនពីរ។

ក៖ កូនពីរអូ៎ចុះគាត់ធ្វើអីគេនៅណុងអ៊ុំ?

ខ៖ ធ្វើរោងចក្រសាច់មាន់។

ក៖ អូ៎ប្រាក់ខែគេអោយច្រើនទេអ៊ុំ?

ខ៖ បានមួយម៉ឺនមួយម៉ឺនជាង។

ក៖ បាទអ៊ុំបាទចុះអើកូនទីពីរនៅថៃដែរ?

ខ៖ កូនទីពីរនៅប៉ៃលិន។

ក៖ ប៉ៃលិនណេះអ៊ុំណេះ?

ខ៖ បាទ!

ក៖ ប៉ុន្តែព្រំដែនដែរតើអ៊ុំណេះ?

ខ៖ ព្រំដែន។

ក៖ អ៊ូគាត់មានគ្រួសារនៅអ៊ុំ?

ខ៖ នៅ។

ក៖ នៅទេហោសប៉ុន្តែអើដូចជាគាត់នៅជាមួយនរណាគេនៅណុងនៅក្នុងរោងចក្រគេម៉ង
ហោស?

ខ៖ ក្រុមហ៊ុន។

ក៖ អ៊ូក្រុមហ៊ុនហោសចុះកូនទីបីនៅភ្នំពេញ

ខ៖ កូនទីបីនៅកំពង់ថ្ម។

ក៖ នៅកំពង់ថ្មហោស?

ខ៖ បាទ!

ក៖ គាត់ធ្វើអីគេនៅណុង?

ខ៖ ធ្វើអង្គការដែរ។ឮ

ក៖ តែគាត់អត់ទាន់មានគ្រួសារដែរ?

ខ៖ នៅដែរ។

ក៖ កូនទីបួន?

ខ៖ កូនទីបួនទៅថៃ។

ក៖ ទៅថៃ?

ខ៖ បាទទៅថៃអាកន្លែងអាបងសាច់មាន់។

ក៖ អូ៎នៅកន្លែងជាមួយគ្នា?

ខ៖ បាទ!

ក៖ តែថៃប្រាក់ខែច្រើនហាសណេះអ៊ុំណេះ?

ខ៖ បាទនៅតែពីរនាក់តាយាយតើសព្វថ្ងៃ។

ក៖ អូ៎ចុះយើងនៅពីរនាក់តាយាយចឹងធ្វើអីគេអ៊ុំ?

ខ៖ គ្មានធ្វើអីធ្វើស្រែហ្នឹងឯង។

ក៖ ធ្វើស្រែណេះអ៊ុំ?

ខ៖ បាទបានលក់ខ្លះចាយដែរ។

ក៖ បាទអ៊ុំបាទចុះអ៊ុំគិតថាដូចជាចឹងកូនបងរបស់អ៊ុំអាយុប៉ុន្មានហើយអ៊ុំ?

ខ៖ អាយុម្ភៃជាងហើយសាមទេដឹង។

ក៖ គាត់ឆ្នាំអីគេអ៊ុំ?

ខ៖ ដឹងឆ្នាំអីទេភ្លេចបាត់ហើយទាល់ម៉ែវាបានដឹង។

ក៖ អូ៎តែអ៊ុំអត់ដឹងច្បាស់ថាគាត់អាយុប៉ុន្មានទេណេះ?

ខ៖ បាទ!

ក៖ ប៉ុន្តែអ៊ុំរៀបអាពាហ៍ពិពាហ៍នៅថ្ងៃខែឆ្នាំណាអ៊ុំចាំអត់?

ខ៖ អត់ចាំទេ។

ក៖ អត់ចាំទេណេះអ៊ុំណេះ?

ខ៖ អត់ចាំ។

ក៖ អូ៎!

ខ៖ នៅក្នុងសៀវភៅបានមាន។

ក៖ បាទអ៊ុំចុះអ៊ុំគិតថាដូចជាចឹងនៅពេលដែរអ៊ុំរៀបអាពាហ៍ពិពាហ៍ជាមួយអើដូចជាភរិយាអ៊ុំហ្នឹងដូចជាអ៊ុំចិត្តចង់រៀបដោយខ្លួនឯងរឺមួយក៏ឪពុកម្តាយជាអ្នករៀបចំអោយអ៊ុំពេលណុង?

ខ៖ ម្តាយរៀបចំអោយ។

ក៖ អូ៎ចឹងណោះអ៊ុំ!

ខ៖ បាទ!

ក៖ អូ៎ចុះពេលហ្នឹងដូចជាមានជាភរិយាអ៊ុំផ្តាប់អត់ផ្តាប់ផ្ទះផ្តាប់អីទេ?
ខ៖ គ្មានផ្តាប់អីទេសារណុងហោស!

ក៖ អូ៎!

ខ៖ ការទៅក៏ស៊ីស្មើគ្នា។

ក៖ អូ៎!

ខ៖ មួយម្ភៃម៉ឺនម្នាក់ៗ។

ក៖ អូ៎ពេលណុងជំនាន់ណាអ៊ុំជំនាន់ប៉ៃតជាងជំនាន់កៅជាងអ៊ុំ?

ខ៖ បាទអើប៉ៃតជាងទេដឹងចុះចំណាងដៃបានលុយបីពាន់។

ក៖ បាទអ៊ុំបាទ!

ខ៖ យើងចាយកាក់មួយកាក់ពីរកាក់។

ក៖ អូ៎!

ខ៖ សម្ភាស?

ក៖ សម្ភាសទាក់ទងពីប្រវត្តិប្រជាជនខ្មែរយើងហាសអ៊ុំចឹងដូចជាសំរាប់អ៊ុំគិតថាអើអ៊ុំពេលហ្នឹងអ៊ុំមានជាជំនូនទេអ៊ុំលក្ខណះជូនហ្នឹងអាហ្នឹងអោយលុយចេញលុយស្មើរៀងខ្លួនណោះអ៊ុំណោះ?

ខ៖ ជូន។

ក៖ អាលក្ខណះថាយើងការហាសយើងអោយលុយស្មើរៀងខ្លួនហោសណេះអ៊ុំណេះ?

ខ៖ បាទពីដើមស្មើគ្នា។

ក៖ អូ៎!

ខ៖ តែគេហាសិបម៉ឺនយើងហាសិបម៉ឺនដែរ។

ក៖ បាទ!

ខ៖ ដល់សព្វថ្ងៃនេះមានតែជូនខាងស្រីវិញ។

ក៖ កាលជំនាន់ណុងអត់មាននរណាគេជូននរណាគេទេណេះ?

ខ៖ បាទកាលណុងខាងប្រុសគេលាដៃទៅខាងប្រុសគេសុំប្រាំតុប្រាំតុ។

ក៖ បាទអ៊ុំត្រូវអ៊ូ៎ចុះអ៊ុំគិតថាដូចជាកាលជំនាន់អ៊ុំនៅក្មេងអ៊ុំធ្លាប់បានរៀនខ្មែរអត់អ៊ុំ?

ខ៖ រៀនដែរ។

ក៖ កាលណុងអ៊ុំរៀនបានថ្នាក់ទីប៉ុន្មានទៅ?

ខ៖ បានថ្នាក់ទីប្រាំបួន។

ក៖ ទីប្រាំបួន?

ខ៖ បាទ!

ក៖ ទីប្រាំបួនជំនាន់ណុងស្មើយើងថ្នាក់ទីបីទីបួនហោសរឺមួយក៏ទីប្រាំបួនម៉ង?

ខ៖ ទីប្រាំបួនជំនាន់ណុងស្មើយើងថ្នាក់ទីដប់សព្វថ្ងៃទេដឹង។

ក៖ អ៊ូ៎ទីដប់ហោស?

ខ៖ បាទកំរិតកាលនោះខ្លាំងជាងយើងសព្វថ្ងៃទៀតអត់មានលុយចាយដើរ។

ក៖ អ៊ូ៎បាទ!

ខ៖ រៀនដើររៀននៅកំពង់ឈើទាលណុងដើរ។

ក៖ អ៎ូងាប់ដើរពីហ្នឹងទៅឆ្ងាយហាសអ៊ុំ?

ខ៖ បាទដាក់បាយខ្ចប់។

ក៖ រួចចុះល្មមទៅដល់ប៉ុន្មាននាទីទៅ?

ខ៖ ទៅដល់ចូលបណ្ដោយ។

ក៖ ទៅដល់ចូលរៀនម៉ង?

ខ៖ បាទ!

ក៖ ចេញពីហ្នឹងម៉ោងបួនទៅដល់ចូលរៀនម៉ោងប្រាំពីរ?

ខ៖ បាទ!

ក៖ រួចប៉ុន្តែយើងទៅៗគ្នាច្រើនអ៊ុំណេះ?

ខ៖ គ្នាច្រើនមួយភូមិមានគ្នាបួនដប់នាក់ទៅ ចេញពីភូមិមានគ្នាដប់នាក់ទៅ។

ក៖ បាទអ៊ុំបាទ!

ខ៖ ខ្ញុំដាំបាយទៅម៉ោងបីម៉ោងបួនចេញទៅហើយដល់ចំការទ្រំដោះខោដោះអាវនាំគ្នាហែលទឹកអត់មានផ្លូងទូកទេ។

ក៖ អ៎ូចុះហែលទៅម៉ង?

ខ៖ ហែល។

ក៖ រួចចុះបើខោអាវយើងស្វឹកអស់ហើយអ៊ុំ?

ខ៖ អត់ទេយើងហែលដៃម្ខាងកាន់ដៃម្ខាង។

ក៖ អ៎ូ!

ខ៖ នេះឥឡូវថៅកែបាស់សព្វថ្ងៃនេះកាន់យូរខ្ញុំបោកអស់។

ក៖ អ៎ូ!

ខ៖ ធ្លាប់ជិះមេគោនេះ។

ក៖ បាទ!

ខ៖ ដល់ខែទឹកដែរមែនខែវស្សាចេះ។

ក៖ បាទអ៊ុំ!

ខ៖ សំបូរទឹកជ្រោះដែរអ៊ូវេទនាណាស់ដល់កូនសព្វថ្ងៃអាលុយក៏មានចាយ អាម៉ូតូក៏មានជិះ បាយក៏មានស៊ីដែរចំអាជំនាន់ឯងអោយវាប្រឹងរៀនវាមិនប្រឹងរៀនទៀត។

ក អត់ប្រឹងរៀនទៀតណោះអ៊ុំ?

ខ៖ សព្វថ្ងៃនេះ។

ក៖ បាទអ៊ុំបាទចុះអ៊ុំគិតថាកាលជំនាន់អ៊ុំរៀនអ៊ុំធ្លាប់មានមិត្តភក្តិស្និទ្ធិស្នាលដែរធំធាត់មកជាមួយគ្នាអត់អ៊ុំ?

ខ៖ គ្មានទេមួយសារណុងហោស!

ក៖ អត់មានទេណោះអ៊ុំណោះ?

ខ៖ បាទ!

ក៖ កូនរបស់អ៊ុំ?

ខ៖ បាទ!

ក៖ អ៊ូរួចចុះអ៊ុំគិតថាចឹងអ៊ុំធ្លាប់ធ្វើស្រែចំការដែរហោសអ៊ុំ?

ខ៖ បាទធ្វើតើមុនធ្វើចំការជាមួយខ្មោចម៉ែ។

ក៖ អ៊ូធ្វើចំការតែស្រែអ៊ុំអត់ដែរធ្វើទេ?

ខ៖ ធ្វើស្រែផងចំការផង។

ក៖ អ៊ូបាទអ៊ុំចុះអ៊ុំគិតថាដូចជាកាលពីក្មេងរហូតមកដល់ឥឡូវការងារអីគេខ្លះដែរអ៊ុំធ្លាប់ធ្វើទៅអ៊ុំ?

ខ៖ ធ្វើអីធ្វើស្រែប្រាំងស្រែវស្សាយើង។

ក៖ បាទ!

ខ៖ មានមុខរបរអីទេ។

ក៖ បាទអ៊ុំបាទចុះអ៊ុំគិតថាសំរាប់ដូចជាលក់ដូរអ៊ុំធ្លាប់លក់ដូរទេ?

ខ៖ មិនដែរលក់អីទេ។

ក៖ លក់ត្រីលក់អីអ៊ុំអត់ដែរដែល?

ខ៖ អូ៎លក់ត្រីលក់ពេលបានទៅលក់មួយគីឡូពីរគីឡូទៅ។

ក៖ អត់បានក៏អត់ទៅនេះ?

ខ៖ បាទលក់នៅឈើទាលហោស!

ក៖ អូ៎ទៅលក់នៅណោះ?

ខ៖ អត់ទេពេលយើងអត់ទិញនៅនោះស៊ីវិញ។

ក៖ អូ៎ចង់និយាយថាបើយើងបានយើងលក់នៅហ្នឹង?

ខ៖ បាទ!

ក៖ តែបើយើងអត់យើងទៅទិញនៅភូមិឈើទាលវិញ?

ខ៖ បាទ!

ក៖ អូ៎ឆ្ងាយ?

ខ៖ ទិញត្រី។

ក៖ អូ៎ឆ្ងាយចុះអ៊ុំគិតថាកាលពីក្មេងរហូតដល់ឥឡូវអ៊ុំធ្លាប់មានចិញ្ចឹមសត្វ មានចិញ្ចឹមមាន់ទា ជ្រូក គោ ក្របីអីអ៊ុំធ្លាប់ចិញ្ចឹមទេ?

ខ៖ បាទចិញ្ចឹមរហូតតើ!

ក៖ ប៉ុន្តែអ៊ុំឥឡូវអ៊ុំនៅចិញ្ចឹមអីគេអ៊ុំ?

ខ៖ ចិញ្ចឹមក្របី។

ក៖ ក្របីហើយហ្នឹងមាន់អ៊ុំ?

ខ៖ មាន់ហើយហ្នឹងឆ្កែ។

ក៖ អូ៎!

ខ៖ ចេះតែចិញ្ចឹមទៅ។

ក៖ តែអ៊ុំចិញ្ចឹមច្រើនណោះអ៊ុំណោះ?

ខ៖ ឆ្កែប្រាំប្រាំមួយ។

ក៖ ចុះក្របី ក្របីច្រើន?

ខ៖ ក្របីមួយដំប៉ក្នុនពីរ។

ក៖ ហើយចុះមាន់ មាន់ច្រើនទេអ៊ុំ?

ខ៖ មាន់បីសំបុក។

ក៖ អូ៎បាទអ៊ុំ!

ខ៖ ចិញ្ចឹមលក្ខណៈគ្រួសារ។

ក៖ បាទអ៊ុំបាទចុះអ៊ុំគិតថាអើដូចជាជីវិតរបស់អ៊ុំអ៊ុំគិតថាមានការផ្លាស់ប្ដូរអើគេខ្លះទៅអ៊ុំទាំងជីវភាព សុខភាព ក្រុមគ្រួសារគិតថាមានការផ្លាស់ប្ដូរអើឥឡូវអ៊ុំ?

ខ៖ គ្មានផ្លាស់ប្ដូរអើក្មួយគ្មានឈឺស្កាត់អីទទេ។

ក៖ ប៉ុន្តែគ្រាន់ថាជីវភាពយើងអើសុខភាពយើងឥឡូវរៀងខ្សត់ខ្សោយជាងមុន ចុះខ្សោយរឺក៏ម៉េច?

ខ៖ បាទខ្សោយៗមឬន។

ក៖ ដោយសារអ៊ុំចាស់ហើយណោះ?

ខ៖ ដោយសារខ្ញុំចាស់ហើយបើថាអោយអេដស៍អីគ្មានទេឈឺខ្យល់វិលមុខទៅកោសខ្យល់ទៅលេបថ្នាំមួយគ្រាប់ទៅបាត់ទៅ?

ក៖ អូ៎បាទអ៊ុំចុះសំរាប់អ៊ុំគិតថាម្ហូបអីគេដែរអ៊ុំចូលចិត្តហូបអ៊ុំ?

ខ៖ អូ៎មិនទៀងទេហូបគ្រប់មុខចង់ស្លម្ជូរ ម្ជូរទៅចង់ស្ងោរក៏ស្ងោរទៅ។

ក៖ អូ៎បាទអ៊ុំចឹងអ៊ុំនៅក្មេងនៅជាមួយគ្នាហោសអ៊ុំនិយាយរួមមិត្តភក្តិគ្នាតាំងពីនៅក្មេងមែនអ៊ុំ?

ខ៖ បងថ្លៃខ្ញុំ។

ក៖ អូ៎បងថ្លៃហោស?

ខ៖ បាទ!

ក៖ អូ៎រួចចុះអ៊ុំគិតថាចឹងអ៊ុំចេះច្រៀងអត់?

ខ៖ អូ៎អត់ចេះខ្ញុំអត់ចេះច្រៀងទេខ្ញុំខាងសិល្បះខ្ញុំហោស!

ក៖ អូ៎អ៊ុំខាងសិល្បះហោស?

ខ៖ បាទខ្ញុំនៅរៀនថ្នាក់ទីប្រាំមួយទីប្រាំហាស!

ក៖ បាទអ៊ុំ!

ខ៖ ដល់ពេលថ្នាក់ទីប្រាំបីទីប្រាំបួនខ្ញុំជាប់លេងទៀត។

ក៖ អូ៎ប៉ុន្តែអ៊ុំជាសិល្បះអ៊ុំលេងជាអីគេអ៊ុំ?

ខ៖ លេងយីកេក៏លេងល្ខោនក៏លេងខ្ញុំអ្នកនៅធ្លុក។

ក៖ អូ៎!

ខ៖ ភ្លេងការក៏លេង។

ក៖ បាទអ៊ុំបាទហើយចុះអាលក្ខណៈថាអើភ្លេងខ្មែរ ភ្លេងសៀមពិពាតអីអ៊ុំលេងទេ?

ខ៖ បាទភ្លេងការពិពាតអីខ្ញុំអត់ដែរលេងទេលេងតែភ្លេងការទេ។

ក៖ អ៊ូចុះអ៊ុំចេះដែរ?

ខ៖ បាទខាងស្គរ ខាងទ្រដើរលេង។

ក៖ ភាគច្រើនទៅលេងនៅណាទៅអ៊ុំ?

ខ៖ លេងតាមរោងការគេការ។

ក៖ អ៊ូបាទអ៊ុំបាទ!

ខ៖ កាលខ្ញុំលេងមួយរោងដប់ពីរម៉ឺន។

ក៖ បាទអ៊ុំ!

ខ៖ ដល់សព្វថ្ងៃមួយរោងសែសិបម៉ឺនអី។

ក៖ អ៊ូបាទអ៊ុំ!

ខ៖ ឥឡូវបាត់គ្នាអស់រលីង។

ក៖ អ៊ូកើតអីអ៊ុំ?

ខ៖ ទំនងទៅអស់ហើយ!

ក៖ អ៊ូចឹងហោស!

ខ៖ ខ្ញុំឈប់លេងទៅ។

ក៖ បាទអ៊ុំ!

ខ៖ ចេះតែទ្រស្គរទៅដឹងលេងនៅណាទៅ។

ក៖ បាទអ៊ុំបាទ!

ខ៖ ហាត់មែនទែន។

ក៖ ចុះអ៊ុំគិតថាអើផ្ទះរបស់អ៊ុំកាលពីតូចផ្ទះម៉េចដល់ពេលឥឡូវនៅជាមួយគ្រួសារផ្ទះម៉េច ទៅអ៊ុំកាលពីអ៊ុំនៅជាមួយឪពុកម្ដាយផ្ទះម៉េចទៅ?

ខ៖ ផ្ទះតូចទេផ្ទះបិខ្ទង។

ក៖ ដល់ពេលឥឡូវអ៊ុំនៅជាមួយប្រពន្ធអ៊ុំជាមួយកូនចៅផ្ទះប៉ុណ្ណឹងណោះអ៊ុំណោះ?

ខ៖ បាទ!

ក៖ ចុះផ្ទះហ្នឹងនរណា..?

ខ៖ ចុះជាងវាអាឈើហោសអានេះ។

ក៖ បាទអ៊ុំ!

ខ៖ អានេះធ្វើដោយញើសឈាមខ្លួនឯង!

ក៖ បាទចុះនរណាគេជាអ្នកជួសជុលសាងសងវាទៅអ៊ុំ?

ខ៖ ពុកក្មេក។

ក៖ អូ៎ប៉ុន្តែអ៊ុំមាននរណាគេដែរចេះធ្វើផ្ទះអត់អ៊ុំ?

ខ៖ បានប្អូនគាត់ជាង។

ក៖ អូ៎ខាងឪពុករបស់អ៊ុំហោស?

ខ៖ បាទឈ

ក៖ អូ៎បាទអ៊ុំបាទចុះអ៊ុំជំនាញអីដែរអ៊ុំស្ទាត់ជំនាញហាសអ៊ុំជំនាញអារឈើ?

ខ៖ អារឈើជំនាញមែនទែន។

ក៖ អូ៎អារឈើ..?

ខ៖ ខាងក្រោមហោស!

ក៖ ចឹងហោសអ៊ុំ?

ខ៖ អារឈើលក់ដូរផងដូរអង្ករផង។

ក៖ នៅណាអ៊ុំអារឈើនៅណា?

ខ៖ ព្រៃកជាំក្រៅភូមិថ្មីហោស!

កះ អ៊ូយើងអារឈើហើយយើងដឹកអីយកមកទៅ?

ខះ រទេះគោ ក្របី។

កះ គោ ក្របីអ៊ូ?

ខះ មែនដូចគោយន្តគេសព្វថ្ងៃណា។

កះ បាទ!

ខះ ធ្លាក់ពីដើមគកោះទុក។

កះ បាទអ៊ុំប៉ុន្តែភាគច្រើនយើងអារមួយថ្ងៃបានប៉ុន្មានទៅ?

ខះ បានប្រាំពីរសន្លឹកប្រាំបីស្លឹក។

កះ បានប្រាំពីរសន្លឹកប្រាំបីសន្លឹកមួយសន្លឹកយើងបានប៉ុន្មានទៅអ៊ុំ?

ខះ មួយស្លឹកបានមួយម៉ែត្រពីរពាន់មួយពាន់ប្រាំពីរពាន់។

កះ ជំនាន់ណុងណោះអ៊ុំជំនាន់ណុងថ្លៃលុយហោស?

ខះ បាទលុយថ្លៃពួកណុងគេធ្វើរទិញកកោះហោស!

កះ អ៊ូឆ្ងាយ?

ខះ ដេកផ្លូវហោស!

កះ អ៊ូ!

ខះ លក់បានខ្លះទៅទិញអង្ករមកខ្លះមកយើងទុកអោយពួកគាត់ខ្លះទៅ។

កះ អ៊ូបាទអ៊ុំបាទចុះអ៊ុំគិតថាឪពុកម្តាយរបស់អ៊ុំធ្លាប់បង្រៀនពីជំនាញអីទៅអ៊ុំអត់?

ខះ មានបង្រៀនអីគ្រាន់គាត់ប្រាប់អោយធ្វើស្រែធ្វើអី។

កះ អ៊ូបាទអ៊ុំចុះអ៊ុំអាចប្រាប់ខ្ញុំអើពីជំនាន់ប៉ុលពតបានទេថាពេលណុងអ៊ុំធ្លាប់ជួបការលំបាក
អីខ្លះពីជំនាន់ប៉ុលពត?

ខះ អ៊ូលំបាកហាសវេទនា។

កៈ គេជំលាសយើងទៅណាអ៊ុំ?

ខៈ ខ្ញុំគេជំលាសទៅនេះណុងអីចាស់ជ្រុំនេះ។

កៈ អ៊ូ!

ខៈ តាមមាត់ស្ទឹងមានទ្រុងសេស្រេច។

កៈ អ៊ូម៉េចចឹង?

ខៈ ដឹងម៉េច..!

កៈ គេ..?

ខៈ ទទួលយួនចូលមកដល់។

កៈ គេអោយមុខសញ្ញាប្រុងយកយើងទៅហោសអ៊ុំ?

ខៈ បាទមួយភូមិចឹងបែកទៅទីនេះដប់គ្រួសារទៅនោះដប់គ្រួសារទៅអន្លុងស្រេច។

កៈ ប៉ុន្តែអន្លុងហ្នឹងនៅពេលដែរគេត្រៀមអោយយើងទៅហ្នឹងតែយួនវៃចូលមកភ្លាមទៅ?

ខៈ បាទជួបយួនទៅកុំអីឈឹងបាត់ទៅហើយ។

កៈ អ៊ូបាទអ៊ុំចុះអ៊ុំគិតថាកាលជំនាន់ណុងម្ហូបអាហារអីម៉េចដែរ?

ខៈ កាលណុងវាជំលាសទៅអង្ករឆ្នាំងបាយខ្លួនយើង។

កៈ អត់ទេពេលជំនាន់ប៉ុលពតហាសអ៊ុំ?

ខៈ បាទលួចខ្ទប់យកទៅ។

កៈ អ៊ូរួចចុះនៅពេលចឹងគេអោយគេជំលាសយើងនៅម្តុំកន្លែងហ្នឹងណេះអ៊ុំណោះ?

ខៈ បាទ!

កៈ មាត់ស្ទឹងចឹង..?

ខៈ ជំរាបលា។

កៈ បាទអ៊ុំបាទរួចចុះដល់ពេលដែរជំលាសចឹងគេអោយយើងធ្វើអីគេទៅ?

ខៈ គេអោយធ្វើអីមួយថ្ងៃៗអង្គុញតែជំនុំគ្នាប៉ុនជំនុំវាមិនចេញគ្នាធ្វើអី។

កៈ ចឹងគេអត់អោយលីសែងអីទេហោសអ៊ុំ?

ខៈ អត់ទេជំលាសទៅហើយប្រុងវ៉ៃចូលអន្លុងហ្នឹង!

កៈ បីឆ្នាំប្រាំបីខែគឺគេអត់អោយធ្វើអីផង?

ខៈ ជំលាសអាចុងក្រោយនេះ។

កៈ អ៎ូ!

ខៈ បីឆ្នាំប្រាំបីខែវែកដីវែកអី។

កៈ អ៎ូតែ..?

ខៈ ដល់អើចុងក្រោយម៉ងវាជំលាសមកទុក។

កៈ ប៉ុន្តែៗយើងវែកដីយើងវែកនៅណា?

ខៈ វែកអីនោះប៉ុន្តែគេវែកហ្នឹងខ្ញុំវែកអីនោះគេថាស្រុកកំពង់ស្វាយ។

កៈ អ៎ូបាទអ៊ុំបាទដល់ពេលយើងៗនៅហ្នឹងយើងវែកដីនៅហ្នឹងទៅណោះអ៊ុំណោះ?

ខៈ បាទគេនៅនេះគេវែកដីនៅនេះមកវែកណាបើណែន។

កៈ អ៎ូបាទអ៊ុំ!

ខៈ អូតាកែ។

កៈ បាទចឹងគេចែកតំបន់គ្នាទៅណោះអ៊ុំណោះ?

ខៈ បាទ!

កៈ រួចចុះបងប្អូនយើងគេអោយទៅណាទៅអ៊ុំ?

ខៈ អាបងធំៗនោះទៅឆ្ងាយៗ។

កៈ អ៊ូ!

ខៈ នៅព្រៃហោសអត់ដែរនៅជុំគ្នាទេ។

កៈ អ៊ូអត់ជុំគ្នា?

ខៈ អត់អោយនៅម៉ែកូនអីទេបំបែកទៅនៅនេះបំបែកទៅនៅនោះ។

កៈ បាទអ៊ុំបាទ!

ខៈ ម្ដាយធ្វើផ្សេងទៅអាកូនធ្វើផ្សេងទៅកូនតូចទៅគេចិញ្ចឹមទៅ។

កៈ អ៊ូ!

ខៈ អាកូនតូចៗហោស!

កៈ រួចចុះឪពុកម្ដាយយើង?

ខៈ ពុកម្ដាយគេជំលាសទៅអស់ហើយ!

កៈ ប៉ុន្ដែឪពុកម្ដាយយើងគេអោយធ្វើអីទៅអ៊ុំ?

ខៈ វែកដីអីឪពុកម្ដាយ។

កៈ វែកដីដែរហោស?

ខៈ បាទចាស់ហើយក៏នៅតែអោយវែកទៀត។

កៈ អ៊ូកាលជំនាន់ប៉ុលពតហ្នឹងយើងអាយុប៉ុន្មានទៅអ៊ុំ?

ខៈ អាយុដប់ប្រាំពីរដប់ប្រាំបីទេដឹង។

កៈ អ៊ូធំហើយចឹង?

ខៈ ធំហើយចុះកងចល័តហើយ!

កៈ អ៊ូចុះកងចល័តហើយ?

ខៈ បាទ!

កៈ មែនកងកុមារទៀតណាហី?

ខៈ បាទ?

កៈ មែនកងកុមារទៀតណាហី?

ខៈ អើលើសកុមារទៀត។

កៈ អ៎ូចឹងចូលគេហៅអីគេយុវជនឈានមុខហីអ៊ុំ?

ខៈ ហៅអោយុវជនឈានមុខហីមើលកុមារឡើងកំលោះហើយ!

កៈ អ៎ូចឹងមានន័យថាយើង..?

ខៈ បាទ!

កៈ ពេលហ្នឹងកំលាំងយើងនៅពេលហើយណោះអ៊ុំណោះ?

ខៈ ពេញ។

កៈ អ៎ូគេអោយយើងហូបអីគេអ៊ុំពេលណុង?

ខៈ បបរហើយ!

កៈ បបរហោស?

ខៈ បាទបបរក្លូនចានប៉ុណ្ណឹងមួយកំប៉ុងគ្នាប្រាំពីរនាក់។

កៈ បាទអ៊ុំបាទចុះអ៊ុំគិតថាចឹងគេអត់មានជំលាសយើងទៅណាផ្សេងទៀតទេក្រៅពីធ្វើការនៅកន្លែងហ្នឹងហើយគេអោយជំលាសយើងអោយប្រុងពិភាក្សាថាចង់យកយើងសំលាប់ចោលម៉ងហោសអ៊ុំ?

ខៈ បាទ!

កៈ អ៎ូប៉ុន្តែចុះបងប្អូនយើងអត់អីទេ?

ខៈ ទាំងអស់។

កៈ ទាំងអស់ហោស?

ខ៖ តាមភូមិគ្រប់ភូមិ។

ក៖ អ៊ូ!

ខ៖ ជំលាសបំបែកគ្នាទាំងអស់អត់មានអោយលើសគ្នាបើនៅខាងសង្គមថ្មីនេះមួយផ្ទះអណ្តូងមួយៗ។

ក៖ អ៊ូត្រៀមវ៉ៃទំលាក់ចូលអណ្តូង?

ខ៖ បាទប្រុងវ៉ៃដាក់ហោងហើយបានយួនចូលដល់ហោស!

ក៖ អ៊ូ!

ខ៖ ខំអីទៅលេងមួយក្រុមគ្រួសារខ្ញុំទាំងអស់តែបីថ្ងៃតើហ្នឹងវាវ៉ៃបញ្ចូលល្ងូ។

ក៖ រួចចុះយួនចូលមកចឹងអើគេមានដាក់ផែនការណ៍អីសំរាប់ថាគេមានចាប់ចំរិតអីធ្វើអីអត់អ៊ុំពេលណុង?

ខ៖ អត់ទេអត់ដឹងផងកាលនេះអ៊ូបើយួនចូលមកឃើញគេជំលាសនេះស្មានតែគេជំលាសអោយធ្វើនេះ គេជំលាសអោយទៅអង្គុយមើលមុខគ្នាមានដឹងអីទេគ្មានអោយពីណា..!

ក៖ បាទអ៊ុំ!

ខ៖ យួនចូលមកដល់ព្រៃក។

ក៖ បាទអ៊ុំ!

ខ៖ ព្រៃកហើយមានអាមេៗវារត់ទៅហើយ!

ក៖ បាទ!

ខ៖ អាមេឃុំអាហុនតែយើងមានរឿងគ្រាប់គ្រួសគ្រាប់ជំពាមបាញ់យួនអត់អោយយួនចាប់បានអាកស៊ីស្មោរទៅ វាភយើងហាសតាមពិតវាបញ្ជូនវាមានអារណា។

ក៖ ប៉ុលពតភយើងកុំអោយយើងទៅតាមយួនហោស?

ខ៖ បាទកាត់ក្បាលយើងធ្វើក្អុលអូសលេង។

ក៖ អ៊ូ!

ខ៖ ចេះតែខ្លាចចុះពីដើមមានដែរឃើញយួនអី។

ក៖ ចឹងមានន័យថាអើខាងប៉ុលពតគេប្រាប់គេបោកយើងកុំអោយយើងទៅតាមយួនណេះ?

ខ៖ បាទ!

ក៖ អូ៎!

ខ៖ ជានយោបាយគេតែពួកខ្ញុំមានខ្លាចណា។

ក៖ បាទអ៊ុំ!

ខ៖ ឃើញយួនមកអរថាជួយយើងហើយលូអោយផុតមួយសន្ទុះដាច់ជ្រុំ។

ក៖ អូ៎ប៉ុន្តែដល់ពេលហើយដល់ពេលដែលយើងចប់ប៉ុលពតហើយយើងមករកគ្នាម៉េចទៅដោយសារពេលហ្នឹងអត់មានទូរស័ព្ទអត់មានអី?

ខ៖ ដល់ពេលចប់ហើយលែងមានពីណានេះបរទេះមករឹងៗតែម្តង។

ក៖ ប៉ុន្តែ..?

ខ៖ ថាយួនចូលមកហើយ!

ក៖ យើងម៉េចដឹងទៅថាបងប្អូនរឺមួយឪពុកម្តាយយើងនៅទៅ?

ខ៖ បែកគ្នាៗអស់ទៅ។

ក៖ ប៉ុន្តែពួកគាត់ម៉េចដឹងដែរទៅដោយសារអត់មានទូរស័ព្ទអត់មានអីគេរកគ្នាកើតផងហ្នឹង?

ខ៖ អត់មាននិយាយអីកើតទេកាលណុងហោស!

ក៖ ដើរសួរគេហោសអ៊ុំ?

ខ៖ មានតែដឹងកន្លែងមកមកផ្ទះឃើញគេមកភូមិចឹងយើងមកភូមិដែរ។

ក៖ បាទអ៊ុំបាទ!

ខ៖ មកភូមិខ្ញុំមានបងប្អូនខ្ញុំនៅស្ទឹងចមនិតមកជួបគ្នានៅវត្តដែរជួបគ្នាទៅក៏សប្បាយចិត្តទាំងអស់គ្នា ខ្ញុំវិញមកដេកនៅជំនៀងមួយយប់។

ក៖ អ្ហូ!

ខ៖ ប៉ុន្តែគ្រាន់ថាអត់ផ្ទះ..!

ក៖ បាទអ៊ុំ!

ខ៖ មកដេកជំនៀងនេះស្នែកឡើងបានមកផ្ទះចាស់ជ្រុំ។

ក៖ បាទអ៊ុំបាទ!

ខ៖ គេថាកាលណុងគេដើរដែរតើ!

ក៖ បាទអ៊ុំ!

ខ៖ ខោមិនខោអាវមិនអាវមកដល់ម៉ែគាត់ថាសក់អើយកូនមកចុះមាននរណាកាត់អីជំនាន់នោះបីឆ្នាំ។

ក៖ បាទប៉ុន្តែមនុស្សស្រីគេអោយកាត់សក់អោយខ្លីហោសអ៊ុំ?
ខ៖ បាទ!

ក៖ អាហ្នឹងគេមានអ្នកគេកាត់សក់អោយហោស?

ខ៖ បាទសម៉ាក់មិត្តហោសកាត់អីគ្មានទេសក់វែងៗកាលចូលឆ្នាំមួយឆ្នាំគេកាត់ម្តង។

ក៖ អ្ហូ!

ខ៖ បាទអោយវាសំរាកកាប់គោជប់លៀងទៅដល់ខែចូលឆ្នាំហាសដល់វាដល់កំណត់ក្មួយអើយដល់ខែក្រោយវាស៊ីផ្លែទ្រព ផ្លែចំបកវាបេះស៊ី។

ក៖ អ្ហូបាទអ៊ុំ!

ខ៖ ហេគាត់សម្គាសជំនាន់យើងពីដើមពីជំនាន់បីឆ្នាំហោស!

ក៖ ចឹងអ៊ុំគិតថានៅពេលដាច់ប៉ុលពតយើងមានការលំបាកអីផ្សេងទៀតទៅអ៊ុំដោយសារជំនាន់ប៉ែតជាងពេលដែរយើងដាច់ប៉ុលពតយើងចាប់ផ្តើមដូរអង្ករដូរអីហាសអ៊ុំ?

ខ៖ បាទស្រួលតិចៗហើយចាយអង្ករហើយនេះហោស!

ក៖ ហ្នឹងយើងលែងរួមទៀតហើយណោះអ៊ុំណោះ?

ខ៖ បាទលែងហើយហ្នឹងយើងបែកហើយ!

ក៖ គ្រប់ក្រុមហោស?

ខ៖ ហ៎ាគ្រប់ក្រុមគ្រាន់បានធូរបន្តិច។

ក៖ បាទអ៊ុំប៉ុន្តែយើងមានការលំបាកអីទៅអ៊ុំពេលហ្នឹងចាប់ផ្តើមធ្វើស្រែធ្វើអីខ្លួនឯង?

ខ៖ ធ្វើស្រែទៅធ្វើស្រែរួមក្រុម។

ក៖ អូ៎!

ខ៖ មានតែធ្វើស្រែរួមក្រុមបានផលមកយើងច្រូតទាំងអស់គ្នាទៅ។

ក៖ អូ៎!

ខ៖ បានផលមកចែកគ្នាទៅជាគ្រួសារ។

ក៖ ចុះអ៊ុំខ្ញុំមានសំនួរមួយដូចជានៅពេលដែរប៉ុលពតគេយកផ្ទះយកដីយើងអស់ហើយនេះ?

ខ៖ បាទ!

ក៖ រួចចុះនៅពេលដែរយើងមកវិញយើងចាប់ដីយកកន្លែងខ្លួនឯងរឺមួយក៏ម៉េច..?

ខ៖ អត់ទេវាអត់យកអីផ្ទះដីអីវាគ្រាន់តែជំលាសយើងដីអីនៅច្រងូៗគ្រប់តែផ្ទះទៅ។

ក៖ អូ៎ដល់ពេលយើងមកយើងយកផ្ទះយើងវិញទៅ?

ខ៖ យើងមកយកផ្ទះវិញ។

ក៖ បាទអ៊ុំ!

ខ៖ វាផ្ទះមួយៗស្ងាត់ឈឹងផ្ទះមួយៗគ្មានមនុស្សទេរួចអាផ្ទះជិតផ្ទះខ្ញុំនោះជិតមណ្ឌលកុមារ សុទ្ធតែកុមារ។

ក៖ អូ៎!

ខ៖ មានតែកុមារចិញ្ចឹមកុមារ។

ក៖ ប៉ុន្តែនៅហ្នឹងអីអត់មានមនុស្សនៅទេ?

ខ៖ បាទ!

ក៖ ចឹងផ្ទះទុកចោល?

ខ៖ ទុកចោល។

ក៖ ដល់ពេលចឹងមានន័យថាយើង..?

ខ៖ គោក្របីក៏ដាក់រួមដែរ។

ក៖ បាទអ៊ុំដល់ពេលចឹងយើងមកវិញយើងមកយកផ្ទះយើងវិញទៅ?

ខ៖ បាទ!

ក៖ ចុះ..?

ខ៖ គេទៅផ្ទះគេទៅយើងមកផ្ទះយើងមក។

ក៖ អើអត់មាននរណាគេដណ្ដើមគ្នាអីណាអីអ៊ុំណោះ?

ខ៖ គ្មាននរណាដណ្ដើមគ្នាទេនេះផ្ទះទួលខាងនេះផ្ទះក្រោលជ្រូកទ្រុកមាន់។

ក៖ អូ៎បាទអ៊ុំ!

ខ៖ បើអាខាងនោះក្រោលគោ ក្រោលក្របី។

ក៖ បាទអ៊ុំបាទ!

ខ៖ គោក្របីដើររកអស់ណាស្គាល់ក្របីយើងទៅក៏ចាប់យកមកវិញមក។

ក៖ អូ៎បាទអ៊ុំ!

ខ៖ គោក្របីគេដាក់រួមមាន់ក៏យកដាក់រួម។

ក៖ បាទអ៊ុំបាទ!

ខ៖ ឆ្នាំងបាយប្រមូលរលីងឆឹងឆ្នាំងបាយអត់មានទុកអោយទេប្រមូលយកទៅធ្វើអើគេធ្វើកន្លែងដាក់រូបសម្ដេចព្រះសីហានុហាស!

ក៖ បាទអ៊ុំ!

ខ៖ លាក់ទុកកញ្ចក់ប៉ុននេះហោសអាកន្លែងនេះ។

ក៖ បាទអ៊ុំ!

ខ៖ គេលាក់ទុកបានដល់ពេលសម្តេចនេះមកក៏មកយកទៅ។

ក៖ រួចម៉េចទៅចឹងអ៊ុំ?

ខ៖ គាត់យកទៅរបស់គាត់រូបស្អាតសម្តេចនៅពីកំលោះហោស។

ក៖ បាទអ៊ុំចុះអ៊ុំគិតថាអើពេលណាដែរយើងចាប់ផ្តើមសប្បាយអ៊ុំ?

ខ៖ អ៎ូចាប់សប្បាយចាប់ពីកៅបីមក។

ក៖ កៅបីណោះអ៊ុំណោះអាលក្ខណៈចប់អ៊ុនតាក់ហ្នឹងណោះអ៊ុំណោះ?

ខ៖ បាទចប់អ៊ុនតាក់បាទ!

ក៖ អ៎ូចុះអ៊ុំគិតថាកាលពីក្មេងអ៊ុំធ្លាប់មានក្តីបំណងរឺមួយក្តីប្រាថ្នាថាធំឡើងអ៊ុំចង់ធ្វើអីមួយអ៊ុំធ្លាប់គិតទេអ៊ុំកាលអ៊ុំនៅរៀនហាស?

ខ៖ គិតតើវាមិនបានស្រួល។

ក៖ អ៎ូបាទអ៊ុំបាទ!

ខ៖ យើងនៅស្រុកស្រែមិនងាយទេ។

ក៖ អ៎ូ!

ខ៖ បើខ្ញុំបំណងខ្ញុំពីក្មេងចង់ចេះសិល្បៈបំណងខ្ញុំ។

ក៖ បាទអ៊ុំ!

ខ៖ ដល់កើតមកក៏ចប់ទៅពុងរៀនកុមារឈានមុខគេរហូត។

ក៖ អ៎ូ!

ខ៖ មួយសារនេះខ្ញុំនៅស្រុកសន្ទុក។

ក៖ បាទអ៊ុំ!

ខ៖ បានខ្ញុំមកប្រាសាទសំបូរវិញមកនៅប្រាសាទសំបូរក៏សំបូរម៉េស។

ក៖ សំបូរមែន?

ខ៖ មកប្រាសាទព្រៃគុកហោសខ្ញុំពួកខ្ញុំសព្វថ្ងៃពលកម្មថ្ងៃព្រហាសត្បិ៍កាំបិត ពូថៅទៅឆាយមួយត្រូសពលកម្មហាស!

ក៖ បាទអ៊ុំ!

ខ៖ ត្រូសមកបង្កើតស្រុក។

ក៖ អូ៎!

ខ៖ កាលខ្ញុំនៅរៀនមធ្យមសិក្សាហោសកន្លែងនេះកន្លែងកំសត់កន្លែងសាលាថៃកន្លែងប្រជាជនយកទៅដាក់នេះឯង!

ក៖ អូ៎!

ខ៖ កងចល័តគេហាស។

ក៖ បាទអ៊ុំ!

ខ៖ ផ្ទះប្រាំបីខ្ទងចឹងគេហូបបាយទៅវែជួងម៉ឺងៗមកដូច..!

ក៖ នាំគ្នាមកហាសណេះអ៊ុំណេះ?

ខ៖ មកហើយកន្លែងកងចល័តខ្ញុំនោះនៅអូរអណ្ដែងអាលែងថាស់កងឡាន។

ក៖ បាទ!

ខ៖ ម៉ឺងលឺប្រ៉ាវចាក់មកទាន់មិនទាន់ប៉ុននិយាយចានដាក់ប៉ុននេះស៊ីអស់។

ក៖ យើងកាលជំនាន់ហ្នឹងយើងមានតែចានមួយសំរាប់ខ្លួនឯងទេនេះអ៊ុំ?

ខ៖ បាទមានចានមួយស្លាបព្រាមួយ។

ក៖ ដល់ពេលហើយយើងហូបហើយយើងលាងខ្លួនឯងទុកខ្លួនឯងទៅ?

ខ៖ បាទ!

កៈ ចុះបើបាត់ចានអត់ហើយចឹង?

ខៈ បាត់ចានអត់ដល់យូរៗឡើងយប់ឡើងដើរលួចបាយក្ដាំងហេវដល់កំណាត់ហាស បាយក្ដាំងតាមដំបូល យកដំបកអីស៊ីទៅដល់ពេលយប់ឡើងវាដាំបាយស៊ីសុទ្ធតែមាន់ពួកនេះ។

កៈ អូ៎អាយើងអត់មានអីទៅ?

ខៈ អត់មានអីទេហុតតែបបរទៅ។

កៈ អូ៎!

ខៈ ហើយសំលទៅ។

កៈ បាទអ៊ុំបាទ!

ខៈ គេទៅវែងដីហើយចង់ទៅរកអាមុខមេមួយសារទៀតវ៉ៃហែង ប៉ុនវាស្រួលត្រង់ចេះជំនាន់នេះកុំអោយវារោគស្រួលអត់មានអំពើអ្នកចេះធ្មប់ចេះអី។

កៈ អូ៎កាលជំនាន់ណុងណោះអ៊ុំណោះ?

ខៈ ចា៎ហ្នឹងហើយ!

កៈ ដល់ពេលឥឡូវម៉ែអ្នកចេះច្រើនហាស?

ខៈ ហ្នឹងហើយឥឡូវខ្លាចណាស់។

កៈ ឥឡូវខ្លាចរឿងហ្នឹង?
ខៈ ចា៎អារបស់មើលមិនឃើញហោះចូលហើយ!

កៈ បាទអ៊ុំ!

ខៈ ហោះចូលហើយអាស្គរអារក្សហែងទៅវ៉ៃអញ់បន្តិចអាគេបញ្ជាទៅហើយជំនាន់នេះវាខ្លាចគេ។

កៈ អូ៎បាទអ៊ុំ!

ខៈ យើងគ្មានអីទេ។

ក៖ ដល់ពេលគ្មានអីចឹង..?

ខ៖ ដល់ពេលសន្តិភាពក៏លែងមានអាការៈគ្រូអារក្សអីក៏គ្មានហ៊ានធ្វើពីណាពីណី។

ក៖ បាទអ៊ុំចឹងប្រហែលជាខ្ញុំមានសំនួរចុងក្រោយមួយអ៊ុំ?

ខ៖ បាទ!

ក៖ បើសិនជាចង់អោយអ៊ុំផ្ដែផ្ដាំទៅកូនចៅជំនាន់ក្រោយៗហាសអ៊ុំគិតថាមានអីដែរចង់ផ្ដែផ្ដាំទៅជំនាន់ក្រោយៗក្មេងៗកូនចៅអ៊ុំអីចឹងហាសអ៊ុំ?

ខ៖ បាទ!

ក៖ ដើម្បីអោយពួកគាត់ខំប្រឹងរៀនដើម្បីអោយពួកគាត់មានអនាគត់ល្អអីចឹងហាសអ៊ុំមានអីចង់ផ្ដែផ្ដាំពួកគាត់ទេអ៊ុំ?

ខ៖ បាទផ្ដាំដែរតើផ្ដាំចេះតែហាមអោយខំប្រឹងរៀនដែរតើផ្ដាំក្មេងសារក្រោយនេះផ្ដាំក្មេងសារក្រោយកូនគេកូនយើងអោយខំប្រឹងទៅ។

ក៖ បាទអ៊ុំ!

ខ៖ អោយបានចេះកាលពីដើមម៉ែឳអោយខំរៀនខំសូត្រកុំអោយមានគេមើលអីណាអីណីជំនាន់នោះខ្ញុំស្ដាប់អេបីស៊ី។

ក៖ បាទអ៊ុំ!

ខ៖ បាទអេបីស៊ីថាយើងអត់ទាន់លំបាកដល់ម៉ែឳយើងទេម៉ែឳយើងលំបាកជាង។

ក៖ បាទអ៊ុំបាទ!

ខ៖ គ្រាន់ថាម៉ែឳយើងផ្ដែផ្ដាំប្រាប់អីទៅកូនកុំអោយដើរខំរៀនខំសូត្រធ្វើម៉េចបានអោយអនាគត់យើងល្អទៅបានហើយ!

ក៖ បាទត្រូវ!

ខ៖ មានកំប្លែងមួយគេថាជំនាន់ប៉ុលពតគេប្រើឳពុកដូចគោដល់អាកូនឆ្លើយថាអើព្រាបកូនព្រាបដូចលលក។

កៈ អ៎ូបាទ!

ខៈ បើខ្ញុំនិយាយមែនលឺតាព្រម្ម៉ាញគាត់និយាយ។

កៈ បាទអុំ!

ខៈ ពេលអាបីស៊ីស្តាប់សុទ្ធតែអត្តន័យហាសរលកតែតូចមួយស្តាប់ម៉ោងដប់ពីរដប់ហើយ!

កៈ អ៎ូចឹងអរគុណច្រើនអុំដែរបានអោយខ្ញុំពិភាក្សាជាមួយអុំតាក់ទងពីប្រវត្តិអុំចឹងហាសអុំ?

ខៈ បាទកុំអោយកើតជំនាន់នោះម្តងទៀតហោស!

កៈ បាទអុំត្រូវអុំ?

ខៈ ដល់ពេលវាចេះគ្រប់គ្នាទៅមានជំនាន់អោយទៅអីរួចទៀត។

កៈ បាទត្រូវអុំ!

ខៈ កាលពីជំនាន់ណុងគេរើសអ្នកចេះនរណាចេះយកទៅសំលាប់ចោលអស់ហាស!

កៈ ត្រូវអុំ?

ខៈ ទុកអាអ្នកល្ងង់អោយដឹកនាំ។

កៈ បាទអុំបាទចឹងអរគុនច្រើន។